ព្រះរាជាណាចក្រកម្ពុជា

<u>តុលាការកំពូល</u> ជាតិ សាសនា ព្រះមហាក្សត្រ

សំណុំរឿងរដ្ឋប្បវេណី

លេខ : ១៩

ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០០១

<u>**សាលដីកា**</u>

លេខ : ៤០

ចុះថ្ងៃទី ០៣ ខែមីនា ឆ្នាំ២០០៣

**នាមនាមប្រជារាស្ត្រខ្មែរ**

**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ដោយមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម ឃឹម ប៉ុណ្ណ ជាប្រធាន

២- លោក ប៉ែន សាវឿន ជាចៅក្រម

៣- លោក គង់ កិរុន ជាចៅក្រម

៤- លោក ស៊ិន ឌឹម ជាចៅក្រម-របាយការណ៍

៥- លោក ជីវ កេង ជាចៅក្រម

៦- លោក ឈឹម ស៊ីផល ជាចៅក្រម

៧- លោក សោម ស៊ីវ័ឍ្ឍ ជាចៅក្រម

៨- លោក ប្រាក់ គឹមសាន ជាចៅក្រម

៩- លោក យស់ សូខឿន ជាចៅក្រម

ក្រឡាបញ្ជី

លោក ស៊ិន ភារៈ

តំណាងមហាអយ្យការ

លោក ឈួន ចាន់ថា ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខ ពីសាលដីកាលេខ៩៨"ឆ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ នៃសំណុំរឿងរដ្ឋប្បវេណីលេខ២៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍រវាង :

-ដើមចោទឈ្មោះម៉ៅ អ៊ិត (ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៥០ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះម៉ៅ ម៉ាង "ស្លាប់" ម្តាយឈ្មោះ នង គុំ "ស្លាប់" មានកូន០៣នាក់ ។

-ចុងចម្លើយឈ្មោះម៉ាង រូ (ម្ចាស់បណ្តឹងសាទុក្ខ) ភេទស្រី អាយុ៤៥ឆ្នាំ ជាតិខ្មែរ មុខរបរធ្វើស្រែ ទីលំនៅសព្វថ្ងៃភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះ

ម៉ៅ ម៉ាង "ស្លាប់" ម្តាយឈ្មោះ ដួង ស៊ីម "ស្លាប់" ប្តីឈ្មោះ មាន ខន មានកូន០៧នាក់ ។

**កម្មវត្ថុបណ្តឹង** : ប្តឹងទាមទារដី

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៤៣២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០របស់ឈ្មោះ ម៉ាង រូ ប្តឹងមិនសុខចិត្តនិងសាលដីការដ្ឋប្បវេណីលេខ៩៨"ឆ"ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សំណុំរឿងរដ្ឋប្បវេណីលេខ ១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ ២០០១ របស់តុលាការកំពូល ។

តាមពាក្យបណ្តឹងចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ ១៩៩៥ របស់ឈ្មោះ ម៉ៅ អ៊ិត ប្តឹងទាមទារដីលំនៅដ្ឋាន ទំហំ២០មគុណ២០ម ពីឈ្មោះ ម៉ាង រូ ដោយសំអាងហេតុថា ដីនេះរដ្ឋអំណាចបានចែកឱ្យខ្លួនតាំងពីឆ្នាំ ១៩៧៩ ហើយត្រូវឈ្មោះ ម៉ាង រូ ដណ្តើមកាន់កាប់កាលពីឆ្នាំ ១៩៩០ ។

បានឃើញ សាលក្រមរដ្ឋប្បវេណីលេខ ១៣"ក" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្តាល ដែលមានខ្លឹមសារដូចតទៅ :

១-ទទួលបណ្តឹងរបស់ដើមចោទឈ្មោះម៉ៅ អ៊ិត ចុះថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ប្រគល់ដីទំនាស់ដែលមានទីតាំងស្ថិតនៅចំណុចភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានទំហំ២០,៣០មគុណ១៨ម មានព្រំប្រទល់ :

- ខាងជើងទល់នឹងផ្លូវ
- ខាងត្បូងទល់នឹង ប៊ី សុខ
- ខាងកើតទល់នឹងផ្លូវ
- ខាងលិចទល់នឹងដីទំនាស់ ម៉ាង រុន ,ម៉ាង រូ

ឱ្យទៅឈ្មោះ ម៉ៅ អ៊ិត កាន់កាប់ប្រើប្រាស់ជាកម្មសិទ្ធិ ។

៣-បង្គាប់ឱ្យឈ្មោះ ម៉ាង រូ បង់ប្រាក់ប្រដាប់ក្តីចំនួន៧.០០០រៀល ប្រាក់នេះបានកាត់យកពីប្រាក់ ដែលដើមចោទបានបង់រួចហើយៗឱ្យឈ្មោះនេះសងទៅដើមចោទវិញ ។

៤-បង្គាប់ឱ្យឈ្មោះ ម៉ាង រូ បង់ពន្ធសមាមាត្រចំនួន៥០០០រៀល ស្មើនឹង១% លើតម្លៃដីទំនាស់ ។

៥-សាលក្រមនេះប្រកាសជាសាធារណៈ ចំពោះមុខគូក្តីបើកផ្លូវប្តឹងឧទ្ធរណ៍ រយៈពេល២ខែ គិតពីថ្ងៃនេះតទៅ ។

- បានឃើញ បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៩៦ របស់ឈ្មោះ ម៉ាង រូ ប្តឹង

មិនសុខចិត្ត និង សាលក្រមរដ្ឋប្បវេណីលេខ ១៣"ភ" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៨៦ របស់តុលាការខេត្តកណ្តាល ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញ សាលដីការដ្ឋប្បវេណីលេខ២៩៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៨៧របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៨៦ របស់ឈ្មោះ ម៉ាង រូ ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៨៦ របស់ឈ្មោះ ម៉ៅ អ៊ិត ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ តែលើកចោល ដោយទាស់ខុសនឹងគតិច្បាប់ ។

៣-បដិសេធសាលក្រមរដ្ឋប្បវេណីលេខ១៣"ភ" ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៨៦ របស់តុលាការខេត្តកណ្តាល ចោលជាអសារបង់ ។

៤-ប្រគល់ដីទំនាស់ទំហំ២០,៣០មគុណ១៨ម មានទីតាំងស្ថិតនៅចំណុចភូមិស្រុកធំ ឃុំជើងកើប ស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ដែលមានព្រំប្រទល់ :

- ខាងជើងទល់នឹងផ្លូវ
- ខាងត្បូងទល់នឹងដី ប៊ុ សុខ
- ខាងកើតទល់នឹងផ្លូវ
- ខាងលិចទល់នឹងដីទំនាស់ ម៉ាង រុន ,ម៉ាង រូ

ឱ្យទៅឈ្មោះម៉ាង រូ កាន់កាប់ ជាកម្មសិទ្ធិតទៅ ។ ប៉ុន្តែបង្គាប់ឱ្យឈ្មោះ ម៉ាង រូ ប្រគល់ប្រាក់ថ្លៃផ្ទះទៅឱ្យឈ្មោះ ម៉ៅ អ៊ិត ចំនួន ៤០០.០០០រៀល(បួនសែនរៀល) វិញ ។

៥-សំរេចកាត់យកប្រាក់ប្រដាប់ក្តី នៅជាន់សាលាឧទ្ធរណ៍ចំនួន ១៣.០០០រៀល ដែលដើមបណ្តឹងឧទ្ធរណ៍ បានបង់ទុករួចហើយ គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្វ៊ីង២.៥៥០រៀល ចំណាយលើការប្រគល់ដីកាកោះ៥.០០០រៀល និង អាជ្ញាធរតុលាការ៥.០០០រៀល ។ កាលបើហួសកំណត់ប្តឹងសាទុក្ខហើយ បង្គាប់ឱ្យឈ្មោះម៉ៅ អ៊ិត សងប្រាក់១៣.០០០រៀល នេះទៅឱ្យឈ្មោះ ម៉ាង រូ វិញ ។ បង្គាប់ឱ្យឈ្មោះ ម៉ៅ អ៊ិត បង់ពន្ធសមាមាត្រ១% នៃតម្លៃដីទំនាស់ និង ឱ្យឈ្មោះ ម៉ាង រូ បង់ពន្ធសមាមាត្រ១% លើតម្លៃប្រាក់៤០០.០០០រៀល ។ ប្រាក់នេះដាក់ចូលថវិការដ្ឋ៨០% និងដាក់ចូលហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស២០% ។

៦-សាលដីកានេះ ជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តីសំរេចបើកផ្លូវប្តឹងសាទុក្ខ ក្នុងកំណត់ច្បាប់ ។

- បានឃើញ បណ្តឹងសាទុក្ខលេខ១៨៦ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៨៧ របស់ឈ្មោះ

ម៉ៅ អ៊ិត ប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ២៩៥ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៧របស់សាលាឧទ្ធរណ៍ លើសេចក្តីសំរេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសំរេច ដូចតទៅ :

១-ទទួលបណ្តឹងសាទុក្ខលេខ១៩៦ ចុះថ្ងៃទី១០ ខែមិថុនា ឆ្នាំ១៩៩៧របស់អ្នកស្រី ម៉ៅ អ៊ិត ទុកជាត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ២៩៥ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ២៣០ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ១៩៩៧ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន១៩.០០០រៀល ដែលអ្នកស្រីម៉ៅ អ៊ិត បានបង់រួចហើយ គឺពន្ធចុះបញ្ជីក្តី និង ពន្ធហ្លឹងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រី ម៉ាង រ៉ូ សងប្រាក់ចំនួន១៩.០០០រៀល នេះទៅឱ្យអ្នកស្រី ម៉ៅ អ៊ិត វិញ ។

៥-សាលដីកានេះ ប្រកាសនាសវនាការ ជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ ។

- បានឃើញ សាលដីការដ្ឋប្បវេណីលេខ៩៨ "ឆ"ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារសំរេច ដូចតទៅ :

១-ទទួលរឿងក្តីលេខ២៦ ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មី ដោយអំណាចសាលដីកាលេខ១៩ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ។

២-តំកល់សាលក្រមលេខ១៣"ក"ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ១៩៩៦ របស់តុលាការខេត្តកណ្តាលទុកជាបានការទាំងមូល ។

៣-កាត់យកប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣.០០០រៀល ប្រាក់នេះចំណាយលើ ពន្ធហ្លឹង និង ពន្ធចុះបញ្ជីក្តីចំនួន ២.៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ចំនួន ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះចំនួន៥.០០០រៀល និងលើអាជ្ញាធរតុលាការ៥.០០០រៀល បូកសរុប ១៣.០០០រៀល ។

សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ កំបាំងមុខចុងចម្លើយ បើកផ្លូវប្តឹងទាស់ និង សាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញ បណ្តឹងសាទុក្ខលើកទី២លេខ៨៣២ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០របស់ឈ្មោះ ម៉ាង រួ ប្តឹងមិនសុខចិត្តនិងសាលដីកាលេខ៩៨ "ធ"ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍លើសេចក្តីសំរេចទាំងមូល ។

បានឃើញ សារណាការពារ ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១ របស់ឈ្មោះ ម៉ាង រួ ។

បានឃើញ សារណាតប ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០១ របស់ឈ្មោះ ម៉ៅ អ៊ិត ។

-បានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថា : រឿងនេះជារឿងវិវាទដីធ្លី សូមក្រុមប្រឹក្សាជំនុំជំរះសំរេចតាមច្បាប់ ។

- បានស្តាប់ចម្លើយអ្នកស្រី ម៉ាង រួ (ម្ចាស់បណ្តឹងសាទុក្ខ) នៅពេលសវនាការថា : ដីទំនាស់នេះ ភូមិ ឃុំចែកឱ្យខ្លួន ខ្លួនមានពាក្យសុំកាន់កាប់ គឺភូមិ-ឃុំប្រគល់ឱ្យខ្លួន ។ ឈ្មោះ ម៉ាង ព្រឹង ជាប្តីរបស់ឈ្មោះ ម៉ៅ អ៊ិត រត់គេចពីទាហាន មិនបានមករស់នៅលើផ្ទះនេះទេ ។

- បានស្តាប់ចម្លើយអ្នកស្រី ម៉ៅ អ៊ិត (ចុងបណ្តឹងសាទុក្ខ) នៅពេលសវនាការថា :ដីនេះជាដីរបស់ខ្លួនពិតប្រាកដ ពេលដែលខ្លួនទៅរកស៊ីនៅភ្នំពេញខ្លួនទុកផ្ទះ និង ដីអោយម្តាយក្មេក ឪពុកក្មេកថែអោយ ។ ពេលដែលឈ្មោះម៉ាង រួ រុះរើផ្ទះខ្លួនបានឃាត់ដែរ តែគាត់មិនស្តាប់នៅតែរុះ ។ ម៉ាង រួ មានដីដោយខ្លួន មួយឡូត៍មានទទឹង២០ម តែគាត់នៅតែរំលោភយកដីរបស់ខ្លួនទៀត ។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់គូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

- យល់ឃើញថាបណ្តឹងសាទុក្ខលេខ៨៣២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០ របស់អ្នកស្រី ម៉ាង រួ ស្ថិតក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលអាចអនុវត្តបានក្នុងរឿងរដ្ឋប្បវេណីផងដែរ ។

- យល់ឃើញថា ការដែលចុងចម្លើយលើករឿងនៅពេលសវនាការនេះ ក៏ដូចជានៅក្នុងសារណាចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០១ របស់អ្នកស្រីថា ដី និង ផ្ទះទំនាស់នេះរដ្ឋអំណាចបានបែងចែកឱ្យអ្នកស្រីនោះជាការពុំត្រឹមត្រូវទេ ពីព្រោះថា អ្នកស្រីបានឆ្លើយទទួលស្គាល់ថា នៅឆ្នាំ១៩៧៩-១៩៨២ ដើមចោទពិតជាបានមករស់នៅ និង សង់លំនៅដ្ឋានលើដីទំនាស់ប្រាកដមែន ។ ដូច្នេះដើមចោទមានសិទ្ធិលើដី និង ផ្ទះទំនាស់នេះតាមមាត្រា២ នៃអនុក្រឹត្យលេខ២៥ អនក្រចុះថ្ងៃទី២២ ខែមេសា ឆ្នាំ១៩៨៩ហើយ ។ម្យ៉ាងទៀតពុំមានភស្តុតាងណាបញ្ជាក់ថា រដ្ឋអំណាចប្រគល់ដីនិងផ្ទះឱ្យអ្នកស្រីទេ ពីព្រោះរដ្ឋអំណាចបានចែកឱ្យអ្នកស្រីនូវដីមួយឡូត៍នៅជិតដីទំនាស់នេះរួចហើយ។

- យល់ឃើញថា សាលាឧទ្ធរណ៍ពុំបានសំរេច អំពីសំណងខូចខាតផ្ទះដែលចុងចម្លើយរុះរើចេញទេ ប៉ុន្តែដើមចោទពុំបានសាទុក្ខពីសាលដីកានេះ ដូច្នេះតុលាការកំពូលពុំមានសមត្ថកិច្ចសំរេចបានឡើយ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩៨ "ធ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ដែលបានសំរេចសេចក្តីមកនេះមានលក្ខណៈត្រឹមត្រូវតាមទំរង់ និង គតិច្បាប់ហើយ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី ទំនោះមុខក្តី**

១- ទទួលបណ្តឹងសាទុក្ខលេខ៤៣២ ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០០របស់អ្នកស្រីម៉ាង រួ ទុកជាត្រឹមត្រូវតាមទំរង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់ ។

២- តម្កល់សាលដីការដ្ឋប្បវេណីលេខ ៩៨"ធ" ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០០០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

៣- រឹបអូសប្រាក់ប្រដាប់ក្តីដែលដើមចោទបានបង់ទុកនៅតុលាការកំពូលចំនួន១៩.០០០រៀល គឺ :

-ពន្ធចុះបញ្ជីក្តី និង ពន្ធហ្វីងចំនួន៤.០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀលសំរាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រីម៉ាង រួ សងប្រាក់ចំនួន១៩.០០០រៀលនេះទៅដើមចោទវិញ ។

បង្គាប់ឱ្យចុងចម្លើយបង់ពន្ធសមាមាត្រ១% លើតម្លៃជាក់ស្តែងនៃដីទំនាស់ ។

៤- សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០៣ ។